ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៧៣/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលសារតែងតាំង លោក Jürg Montani ជាប្រធានគណៈប្រតិភូថ្នាក់តំបន់របស់ ICRC ប្រចាំកម្ពុជា

នៅព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានទទួលជួបសម្ដែងការគួរសម និងទទួលសារតាំងពី**លោក Jürg Montani ប្រធានគណៈប្រតិភូថ្នាក់តំបន់នៃកាកបាទក្រហមអន្តរជាតិ** (ICRC) នៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ក្នុងឱកាសជំនួបនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** អបអរសាទរចំពោះ**លោក Montani** ដែលត្រូវបានតែងតាំងជាប្រធានគណៈប្រតិភូថ្នាក់តំបន់នៃ ICRC ប្រចាំប្រទេសចំនួន ៧ ដែលក្នុងនោះមានកម្ពុជាផងដែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះបទពិសោធន៍របស់**លោក Montani** ក្នុងការងារមនុស្សធម៌ និងសកម្មភាពមនុស្សធម៌ជាច្រើនរបស់ ICRC នៅកម្ពុជាក្នុងរយៈពេលជាង ៥០ឆ្នាំមកនេះ។

ចំពោះកិច្ចសហប្រតិបត្តិការបច្ចុប្បន្នរវាងកម្ពុជា និង ICRC **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះ ICRC ដែលបានជួយគាំទ្រលើ៖ ១) ការលើកកម្ពស់សុខុមាលភាពរបស់អ្នកជាប់ឃុំ ២) កម្មវិធីស្តារនីតិសម្បទាសម្រាប់ជនពិការ ៣) កិច្ចសហប្រតិបត្តិការជាមួយកាកបាទក្រហមកម្ពុជា និង ៤) ការលើកកម្ពស់ច្បាប់មនុស្សធម៌អន្តរជាតិ (International Humanitarian Law-IHL)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន**លោក Montani** ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំការចូលជាសមាជិកនៃគំនិតផ្តួចផ្តើមសកល "Global Initiative to Galvanize Political Commitment to IHL" និងចូលរួមក្នុងយន្តការការងារ (Work Stream) របស់ ICRC ផងដែរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូន**លោក Montani** អំពីបច្ចុប្បន្នភាព និងការវិវត្តនៃជម្លោះកម្ពុជា-ថៃ និងបានបញ្ជាក់បន្ថែមថា ការវាយប្រហារដោយទ័ពថៃមកលើកម្ពុជាចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ដែលបានពង្រីកតាមផ្លូវគោក ផ្លូវអាកាស និងផ្លូវសមុទ្រ ជាមួយនឹងអាវុធធុនធ្ងន់គ្រប់ប្រភេទ រួមទាំងយន្តហោះចម្បាំង F-16 និងឧស្ម័នពុល បានបណ្តាលឱ្យបាត់បង់ជីវិត និងរបួសជនស៊ីវិលជាច្រើននាក់ ព្រមទាំងជនភៀសសឹករាប់សែននាក់ ហើយក៏បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស៊ីវិល ប្រាសាទ និងសម្បត្តិបេតិកភណ្ឌរបស់កម្ពុជា។

**លោក** Montani បានជម្រាបជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** អំពីដំណើរចុះសួរសុខទុក្ខទាហានកម្ពុជាចំនួន ១៨រូប ជាលើកទី៤។ យោងតាមដំណើរទស្សនកិច្ចនេះ លោកបានបញ្ជាក់ថា ទាហានកម្ពុជាទាំង ១៨រូប ដែលកំពុងស្ថិតក្រោមការឃុំគ្រងរបស់ភាគីថៃ មានសុវត្ថិភាព និងមានសុខភាពល្អជាធម្មតា។ លោកបានបន្ថែមថា ICRC បានជួយសម្រួលដល់ការទាក់ទងរវាងទាហានទាំង ១៨រូប និងក្រុមគ្រួសាររបស់ ពួកគាត់ តាមរយៈការសម្របសម្រួលរបស់កាកបាទក្រហមកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** អរគុណ ICRC ដែលបន្តតាមដានសុខុមាលភាព សុវត្ថិភាព និងលក្ខខណ្ឌរស់នៅរបស់ទាហានកម្ពុជាទាំង ១៨រូប។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីអំពីជំហរកម្ពុជាចង់ឱ្យការប្រយុទ្ធគ្នាត្រូវបានបញ្ចប់ដើម្បីអនុញ្ញាតឱ្យប្រជាជនអាចវិលត្រឡប់ទៅលំនៅឋានវិញ និងវិលត្រឡប់ទៅរកការគោរព និងអនុវត្តពេញលេញតាមលក្ខខណ្ឌនៃបទឈប់បាញ់ និងស្មារតីនៃសេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជា-ថៃ នៅទីក្រុងគួឡាឡាំពួ ប្រកបដោយសុច្ឆន្ទៈខ្ពស់បំផុត៕

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៥